ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ២៧ អយក. សណន

# សេចក្តីណែនាំ
## ស្តីពី
## ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល

បន្ទាប់ពីក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញកម្មវិធីកំណែទម្រង់ស៊ីជម្រៅ វិស័យអប់រំ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យអប់រំទទួលបាននូវការចាប់អារម្មណ៍ខ្លាំងពីអ្នកពាក់ព័ន្ធ ជាពិសេសសិស្សានុសិស្ស និងអាណាព្យាបាល។ ដើម្បីរក្សាជំនឿទុកចិត្តនេះឲ្យបានស្ថិតស្ថេរ ក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោម ៖

១. នាយក នាយិកាសាលាគ្រប់ភូមិសិក្សាទាំងអស់ត្រូវពង្រឹងការងារកសាងផែនការ និងការគ្រប់គ្រងសាលារៀនផ្អែកលើឯកសារ និងវិធីសាស្ត្រត្រឹមត្រូវដែលបានបំប៉នរួចមកហើយដូចជាៈ
   ក. ការគ្រប់គ្រងសាលារៀនផ្អែកលើព័ត៌មានដែលមាន៥ផ្នែក បានបោះពុម្ពក្នុងឆ្នាំ២០០០។
   ខ. កំណែលម្អសាលារៀនសៀវភៅជំនួយសម្រាប់នាយកសាលាបានបោះពុម្ពក្នុងឆ្នាំ២០០៨។
   គ. ការគ្រប់គ្រង រដ្ឋបាល បំណិនវិជ្ជាជីវៈ បានបោះពុម្ពក្នុងឆ្នាំ២០០៩ ។
   ឃ. សៀវភៅណែនាំស្តីពីការអនុវត្ត និងការគ្រប់គ្រងហិរញ្ញវត្ថុ ជំនួយដើម្បីកែលម្អសាលារៀន សម្រាប់ធ្វើឲ្យប្រសើរឡើងការអប់រំនៅតាមសាលារៀនបានបោះពុម្ពក្នុងឆ្នាំ២០១៣ ជាដើម។

២. នាយក នាយិកាសាលាត្រូវជ្រើសរើសយកឯកសារ និងវិធីសាស្ត្រណាមួយដែលឆ្លើយតបទៅបញ្ហាប្រឈមដែលកំពុងជួបប្រទះ ដូចជាសិស្សរៀនត្រួតថ្នាក់ សិស្សបោះបង់ការសិក្សា លទ្ធផលតេស្តភាសាខ្មែរ គណិតវិទ្យាមានកម្រិតទាបនៅបឋមសិក្សា សិស្សចូលរៀនមានចំនួនតិច សិស្សបោះបង់ការសិក្សាច្រើន លទ្ធផលប្រឡងថ្នាក់ទី១២ មានចំនួនតិចជាដើម ។

៣. នាយក នាយិកាសាលាទាំងអស់ ត្រូវរៀបចំដំណើរការរៀន និងបង្រៀនឲ្យមានប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសអប់រំស្មើៗគ្នាដល់សិស្សានុសិស្ស ទោះបីសិស្សស្ថិតក្នុងស្ថានភាពណាក៏ដោយ ក្នុងការបណ្តុះបណ្តាលឲ្យបានពេញលេញ ដើម្បីក្លាយជាមនុស្សមានចំណេះដឹង សីលធម៌ ឥរិយាបថថ្លៃថ្នូរ ត្រៀមខ្លួនចូលរួមចំណែកអភិវឌ្ឍសង្គម សេដ្ឋកិច្ចផ្អែកលើពុទ្ធិនាពេលអនាគត ។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៥៥១ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

៤. នាយក  នាយិកាសាលាទាំងអស់ត្រូវធ្វើការវាយតម្លៃគ្រូបង្រៀនឲ្យបានត្រឹមត្រូវផ្អែកលើសមត្ថភាពបទពិសោធ និងលទ្ធផលសិក្សារបស់សិស្សដូចជា ពិន្ទុប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ ក្នុងការលើកទឹកចិត្តគ្រូបង្រៀនដោយផ្អែកតាមការណែនាំផ្សេងៗ ។

៥. នាយក នាយិកាសាលាទាំងអស់  ត្រូវប្រកាន់ភ្ជាប់គោលការណ៍អភិបាលកិច្ចល្អ ពោលគឺតម្លាភាព គណនេយ្យភាព  និងការចូលរួម  ក្នុងការចាត់ចែងប្រើប្រាស់ធនធានមនុស្ស  ធនធានហិរញ្ញវត្ថុ សម្ភារូបវត្ថុ និងដីធ្លី ជៀសវាងដាច់ខាតការកើតមានហេតុការណ៍អសកម្មដោយប្រការណាមួយ ។

៦. លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ខណ្ឌ ស្រុក ត្រូវជួយសម្របសម្រួលក្នុងការរៀបចំផែនការ និងជួយតាមដានការអនុវត្តផែនការដើម្បីឲ្យប្រាកដថាការដោះស្រាយបញ្ហាទាំងឡាយ នឹងរួមចំណែកដល់ការរីកចម្រើនវិស័យអប់រំ តាមរាជធានី-ខេត្ត ក្រុង ខណ្ឌ ស្រុក ព្រមទាំងឈានដល់ការសម្រេចចំណុចដៅថ្នាក់ជាតិផងដែរ ។

ក្រសួងអប់រំ យុវជន និងកីឡា មានសង្ឃឹមយ៉ាងមុតមាំលើស្មារតី និងការប្តេជ្ញាចិត្តខ្ពស់របស់នាយក  នាយិកាសាលារៀនទាំងអស់ក្នុងការអនុវត្តខ្លឹមសារសេចក្តីណែនាំខាងលើឲ្យទទួលបានជោគជ័យ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានពាក់ព័ន្ធ
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

"ដើម្បីជ្រាបជាព័ត៌មាន"

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ក្រុង ស្រុក
- គ្រប់គ្រឹះស្ថានសិក្សា

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ ឯកសារ អគ.អរ